# ព្រះរាជក្រម

# ស្តីពី

# ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នស/រកម/០៦៩៩/០៩

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយ ប្រើវិសោធនកម្ម នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាពុំទាន់មានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់ របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របទាំងស្រុង នឹងរដ្ឋធម្មនុញ្ញ មានសេចក្តីទាំងស្រុង ដូចតទៅ :

មាត្រា ១ :

ត្រូវបានបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យ រៀបចំដែនដី នគរូបនីយកម្ម និងសំណ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអម ដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ :

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ :

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានទទួលបង្គំថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១២៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ឈាង តាន់**